**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រារព្ធទិវាសន្តិភាពអន្តរជាតិ លើកទី២២
# ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤

យោងតាមផែនការណែនាំលេខ ០៩/២០២៤ គជបអ ចុះនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤ របស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ស្តីពីការរៀបចំទិវាសន្តិភាពអន្តរជាតិ លើកទី២២ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនគ្រប់អង្គភាពក្រោមឱវាទ មន្ត្រីរាជការ បុគ្គលិក កម្មករនិយោជិត ព្រមទាំងនិយោជកទាំងអស់ឱ្យបានជ្រាបថា ទិវាសន្តិភាពអន្តរជាតិត្រូវបានរៀបចំឡើងនៅថ្ងៃទី២១ ខែកញ្ញា ជារៀងរាល់ឆ្នាំ ក្នុងគោលបំណងពង្រឹងឧត្តមគតិសន្តិភាពរបស់ប្រជាជាតិ និងប្រជាជនទាំងអស់ក្នុងពិភពលោក សំដៅកាត់បន្ថយភាពតានតឹង ដោយអំពាវនាវឱ្យគ្រប់ប្រជាជាតិ និងប្រជាជនទាំងអស់បញ្ឈប់អំពើហិង្សា និងភាពប្រទូសរ៉ាយ ដែលបង្កឱ្យមានវិវាទ។

ឆ្នាំនេះជាលើកទី២២ ដែលទិវានេះត្រូវបានប្រារព្ធឡើងក្រោមមូលបទ **"ការបណ្តុះវប្បធម៌សន្តិភាព"** ដែលឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃការបណ្តុះស្មារតី និងវប្បធម៌សន្តិភាព ទៅកាន់សហគមន៍គ្រប់ជំនាន់ តាមរយៈយន្តការអប់រំផ្លូវការ និងក្រៅផ្លូវការនានា នៅក្នុងប្រទេសនីមួយៗលើសកលលោក និងបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្នុងការថែរក្សា **"សន្តិភាព"** និងការតម្កល់ **"សន្តិភាព"** ជាគុណតម្លៃខ្ពស់បំផុត គឺគ្មានការប្រែប្រួលជាដាច់ខាត ទោះបីក្នុងតម្លៃណាក៏ដោយ។

ក្នុងន័យនេះ ដើម្បីអបអរសាទរ និងបំផុសមន្ត្រីរាជការ បុគ្គលិក កម្មករនិយោជិត ព្រមទាំងនិយោជកទាំងអស់ ឱ្យយល់ដឹងអំពីអត្ថន័យទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ជាទិវាបញ្ឈប់ការផ្ទុះអាវុធទូទាំងសកលលោក ក្រសួងសូមណែនាំដល់គ្រប់អង្គភាពក្រោមឱវាទ និងសហគ្រាស គ្រឹះស្ថាន តុបតែងលម្អ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក និងបំភ្លឺភ្លើងពណ៌នៅតាមអង្គភាពរៀងៗខ្លួន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា គ្រប់អង្គភាពក្រោមឱវាទ មន្ត្រីរាជការ បុគ្គលិក កម្មករនិយោជិត ព្រមទាំងនិយោជកទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។ nea

ថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំរោង ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤